**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**កំពត**

**សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៧០**
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨
សំណុំរឿងស៊ើបសួរលេខ ៣៣៣
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨
សំណុំរឿងជំនុំជម្រះលេខ ១២៩
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩
**សាលក្រមព្រហ្មទណ្ឌលេខ ២៥៦ "ខ"**
ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

បានបើកសវនាការជាសាធារណៈនៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទបើកសវនាការថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ។
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពត

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៤៧០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទៈ

ក.ឈ្មោះ [redacted] រិទ្ធី ហៅអៀន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កើតនៅ[redacted] ខេត្តកោះកុង និងទីលំនៅបច្ចុប្បន្ននៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ឪពុកឈ្មោះ[redacted] សំអុល (រស់), ម្តាយឈ្មោះ [redacted] គឹមហាក់ (រស់) នៅលីវ ជានីតិជន ទោសពីមុនមាន ។ (ក្នុងឃុំ)

ខ.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន កាន់សាសនាព្រះពុទ្ធ កើតនៅភូ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] សាន (រស់), ម្តាយឈ្មោះ [redacted] ពុច (រស់) នៅលីវ ជាអនីតិជន ទោសពីមុនមាន ។ (ក្នុងឃុំ)

គ.ឈ្មោះ[redacted] រតនា ហៅឆាង ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កើតនៅភូមិ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] ប៊ុនធឿន (ស្លាប់), ម្តាយឈ្មោះ[redacted] សាវៀន (រស់) នៅលីវ ជានីតិជន ទោសពីមុនមាន ។ (ក្នុងឃុំ)

Scanned with CamScanner

ឃ.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកកាស៊ីណូ កាន់សាសនាព្រះពុទ្ធ កើតនៅភូមិ [redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ម៉ុន (រស់), ម្តាយឈ្មោះ [redacted] ន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនមាន ។ (ក្នុងឃុំ)

ដោយមានលោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ ។

ដោយមានលោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ ។

ដោយមានលោកស្រី [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ ។

ត្រូវបានចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៣៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពត។

## ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

ឈ្មោះ [redacted] NARAYAN ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិឥណ្ឌា មុខរបរអ្នកចេញម៉ូត រស់នៅទីក្រុងដាវីស សហរដ្ឋអាមេរិក ។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង២១ និង០០នាទី មានករណី លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) បានកើតឡើងនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ដែលបង្កឡើងដោយជនសង្ស័យចំនួន០៤នាក់មាន៖១.ឈ្មោះ [redacted] រិទ្ធី ហៅអៀន ភេទប្រុស អាយុ ១៨ឆ្នាំ, ២.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៧ឆ្នាំ, ៣.ឈ្មោះ [redacted] រតនា ហៅឆាង ភេទប្រុស អាយុ ១៩ឆ្នាំ និង៤.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ។ ដោយក្រុមជនសង្ស័យបានធ្វើសកម្មភាពឆក់កាបូបជនរងគ្រោះឈ្មោះ [redacted] NARAYAN ភេទស្រី អាយុ ២៤ឆ្នាំ បណ្តាលឲ្យជនរងគ្រោះបាត់បង់សម្ភារៈមួយចំនួនមានប្រាក់ចំនួន ១២០,០០០រៀល, លិខិតឆ្លងដែនចំនួន ០១, ប័ណ្ណបើកប្រាក់ចំនួន០១, ប័ណ្ណបើកបរចំនួន០១, អត្តសញ្ញាណប័ណ្ណចំនួន០១ និងកាបូបស្ពាយចំនួន០១ ។ បន្ទាប់ពីធ្វើសកម្មភាពរួច ជនសង្ស័យទាំង០៤នាក់គេចខ្លួនបាត់ លុះក្រោយមកសមត្ថកិច្ចឃាត់ខ្លួនបានជនសង្ស័យទាំងបួន នាក់ក្នុងករណីឆក់កាបូបផ្សេងទៀតតែម្តង ។

## នាពេលសវនាការក្រោយពីបាន

- ស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង៤នាក់
- ស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ស្តាប់អំណានឯកសាររបាយការណ៍ និងកំណត់ហេតុផ្សេងទៀតដែលមានក្នុងសំណុំរឿង
- ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ពិនិត្យភស្តុតាងនិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

## យល់ឃើញថា

១.កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ មានអំពើ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ប្រាកដមែន ។

២.តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៣៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ និងតាមដីកាសន្និដ្ឋានស្ថាពរលេខ ០៥ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់តំណាងអយ្យការចោទប្រកាន់៖១.ឈ្មោះ [redacted] រិទ្ធី ហៅអឿន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ, ២.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន, ៣.ឈ្មោះ [redacted] រតនា ហៅឆាង ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ និង៤.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកកាស៊ីណូ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ។ បទល្មើសព្រហ្មទណ្ឌមាន ចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ហៅអឿន បានឆ្លើយនាពេលសវនាការថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ខ្លួនមានគ្នា៤នាក់ ឈ្មោះ [redacted] ឈ្មោះហុង ឈ្មោះ [redacted] និងខ្លួនផ្ទាល់ បានឆក់កាបូបជនបរទេសដើរពីរនាក់ ស្រីប្រុស នៅរង្វង់មូលរែកអំបិល និងកន្លែងផ្សេងទៀត ឆក់បានពួកខ្លួនជិះម៉ូតូគេចខ្លួន អាចឲ្យតុលាការពិចារណាបាន ។

.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ហុង បានឆ្លើយនាពេលសវនាការថាខ្លួបានប្រ. ព្រឹត្តដូចការចោទប្រកាន់មែន ខ្លួនទទួលស្គាល់ថា ខ្លួនធ្លាប់ឆក់កាបូបគេចំនួន៧លើកមែនពេលធ្វើសកម្មភាពមានគ្នា៤នាក់នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ខ្លួនមិនធ្វើសកម្មភាពដោយផ្ទាល់ទេ អាចឲ្យតុលាការពិចារណាបាន ។

.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រតនា ហៅឆាង បានឆ្លើយនាពេលសវនាការថាខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន ពេលធ្វើសកម្មភាពខ្លួនភ្លេចថ្ងៃ ខែ ឆ្នាំ ដោយយូរពេក ឆក់ម្តងៗមានគ្នា៤នាក់ដដែល អាចឲ្យតុលាការពិចារណាបាន ។

.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង បានឆ្លើយនាពេលសវនាការថាខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ខ្លួនបានឆក់កាបូបគេ តែខ្លួនមិនចាំកន្លែងពេលធ្វើសកម្មភាពមានគ្នា៤នាក់ ឈ្មោះឆាង ឈ្មោះហុង ឈ្មោះអឿន និងខ្លួនផ្ទាល់ អាចឲ្យតុលាការពិចារណាបាន ។

.ស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] NARAYAN នាពេលសវនាការថា នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ខ្លួនបានហូបម្ហូបខ្មែរ ជាមួយឈ្មោះ [redacted] ដេវីត

ភេទស្រី ជាតិអាមេរិច រួចខ្លួនដើរមកកន្លែងស្នាក់ បន្តិចក៏មានម៉ូតូមួយគ្រឿងមិនស្គាល់ម៉ាកជិះគ្នាពីរនាក់ បានធ្វើសកម្មភាពឆក់ថង់ក្រណាត់ពីលើស្មារបស់ខ្លួនតែម្តង ខ្លួនបាត់បង់រួមមានៈ លុយ២៥០ ដុល្លារ, លុយ១២.០០០.០០០រៀល ,លិខិតឆ្លងដែនរបស់ខ្លួនចំនួន០១,ប័ណ្ណបើកលុយផលិតនៅសហរដ្ឋអាមេរិចចំនួន០១, ប័ណ្ណបើកបរផលិតនៅសហរដ្ឋអាមេរិចចំនួន០១, អត្តសញ្ញាប័ណ្ណចំនួន ០១ ជួយស្រាវជ្រាវរកសំភារៈនិងលុយរបស់ខ្លួនដែលបាត់បង់ អាចឲ្យតុលាការពិចារណាបាន ។

៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន ក្រោយពីបានស្តាប់ចម្លើយសារភាពជនជាប់ចោទ និងស្តាប់អំណានដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការរួចមកឃើញថា ជនជាប់ចោទ១. ឈ្មោះ [redacted] រិទ្ធី ហៅអឿន, ២.ឈ្មោះ [redacted] ហុង, ៣.ឈ្មោះ [redacted] រតនា ហៅឆាង និង៤.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះតំណាងអយ្យការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ០៥ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ទុកជាបានការដដែលប្តឹងសុំឲ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា ។

៥.មេធាវីធ្វើសេចក្តីសន្និដ្ឋាន ក្រោយពីបានស្តាប់ចម្លើយសារភាពជនជាប់ចោទ និងស្តាប់អំណានដើមបណ្តឹងរដ្ឋប្បវេណីនាពេលសវនាការរួចមកឃើញថា ជនជាប់ចោទទាំងនេះខ្លះសារភាពដូចជាឈ្មោះ[redacted]រតនា ហៅឆាងថា ធ្វើសកម្មភាព០៧លើក ឈ្មោះ[redacted] រិទ្ធី ហៅអឿន០២លើក ឈ្មោះ[redacted]ហុង ០២លើក ឈ្មោះ[redacted] ដារិទ្ធ ហៅម៉េង ០១លើក នាក់ទាំង៤នាក់ បានឆ្លើយថា សមត្ថកិច្ចវាយ តែអយ្យការ និងចៅក្រមស៊ើបសួរថា រក្សាចម្លើយនៅសមត្ថកិច្ចដដែល អំពើឆក់នោះជាច្រើនលើកច្រើនសារមែន ហើយសុំលោកប្រធានក្រុមប្រឹក្សាកែមាត្រា៣៥៧ មក៣៥៦វិញ ។ ចំពោះជនជាប់ចោទពីរនាក់ជាអនីតិជន និងសុំឲ្យលោកប្រធានក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំង៤នាក់ ការលើកឡើងរបស់មេធាវីកែប្រែមាត្រា ពុំមានធាតុផ្សំ ពីមាត្រា៣៥៦ទេ តែធាតុផ្សំហិង្សានៅមាត្រា ៣៥៧ វិញ ។

៦.ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស ដោយជនជាប់ចោទទាំង៤នាក់សុទ្ធតែបានសារភាព ពេលសមត្ថកិច្ចហើយការប្រព្រឹត្តនោះសុទ្ធតែមានចេតនាប្រាកដមែន ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទមានស្មារតីគ្រប់គ្រាន់នូវអំពើរបស់ខ្លួន ។

៧.អំពើល្មើសរបស់ជនជាប់ចោទបានប្រព្រឹត្តមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៨.មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ១. ឈ្មោះ [redacted] រិទ្ធី ហៅអឿន ជនជាតិខ្មែរ, ២.ឈ្មោះ [redacted] ហុង ជនជាតិខ្មែរ, ៣.ឈ្មោះ [redacted] រតនា ហៅឆាង ជនជាតិខ្មែរ និង ៤.ឈ្មោះ[redacted] ដារិទ្ធ ហៅម៉េង ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ

Scanned with CamScanner

២០១៧ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៩.ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ទាមទារសំណងការខូចខាតនោះ សុំនៅសមត្ថកិច្ច ពុំបានមកបំភ្លឺនៅនីតិវិធីតុលាការឡើយគប្បីទុកសិទ្ធិឲ្យប្តឹងទាមទារនៅតុលាការរដ្ឋប្បវេណី ។

១០.ជនជាប់ចោទឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ជាអនីតិជនការយល់ដឹងមានកំរិត គប្បីតុលាការពិចារណាពីទណ្ឌកម្ម។

## ដូច្នេះសម្រេច

១.ផ្តន្ទាទោស:

ក.ឈ្មោះ [redacted] រិទ្ធី ហៅអឿន ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ (បីឆ្នាំ) ។

ខ.ឈ្មោះ [redacted] រតនា ហៅឆាង ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ (បីឆ្នាំ) ។

គ.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ពីរឆ្នាំ (ពីរឆ្នាំ) ។

ឃ.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ពីរឆ្នាំ (ពីរឆ្នាំ) ។

ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ១.ឈ្មោះ [redacted] រិទ្ធី ហៅអឿន, ២.ឈ្មោះ [redacted] ហុង, ៣.ឈ្មោះ [redacted] រតនា ហៅឆាង និង៤.ឈ្មោះ [redacted] ដារិទ្ធ ហៅម៉េង និងកំបាំងមុខដើមបណ្តឹងឈ្មោះ [redacted] NARAYAN ទុកពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខានិង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កំពត,ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១៩
ក្រឡាបញ្ជី

[redacted]